**ព្រះរាជបញ្ជាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ជា រិទ្ធីឈុត** ជាប្រតិភូរាជរដ្ឋាភិបាល ប្រចាំទីក្រុងកែប ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ត្រូវទុកជានិរាករណ៍នូវព្រះរាជក្រឹត្យ នស/រកត/០៥៩៤/៣៣ស្ទួន ចុះថ្ងៃទី ១៧_៥_១៩៩៤ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

* * *

# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ១០ អនក្រ.បក**

**ស្តីពីការអនុវត្តន៍**

**របបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាព**

**ការងារចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ**

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៧ នស.៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និង របបសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន
- តាមសេចក្តីបង្គំទូលស្នើសុំ និងស្នើសុំអំពី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១** ._យោធិនទាំង ២ ភេទនៃកងយោធពលខេមរភូមិន្ទ អាចទទួលរបបសោធននិវត្តន៍ជាប្រចាំខែបានលុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា ១ និងមាត្រា ២ ជំពូក ទី ១ នៃព្រះរាជក្រម ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ។

ចំពោះរយៈពេលដែលយោធិនទាំង ២ ភេទបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬ ការងារប៉ះពាល់សុខភាព ដូចមានចែងក្នុងមាត្រា ២ ចំណុច ក ( ២ ៣ ៤ ) និង ចំណុច ខ ( ២ ) ជំពូកទី ១ នៃព្រះរាជក្រម គឺជារយៈពេលដែលបានបំរើការងារជាប់រហូត ហើយបានបំពេញតាមល័ក្ខខ័ណ្ឌនីមួយៗនោះ ទើបអាចទទួលរបបសោធននិវត្តន៍បាន ។

**មាត្រា ២** ._របៀបគិតរយៈពេលបំរើការងារ ព្រមទាំងការកំណត់តំបន់លំបាក ការងារគ្រោះថ្នាក់ ឬ ការងារប៉ះពាល់សុខភាពរបស់យោធិនម្នាក់ៗ នៃកងយោធពលខេមរភូមិន្ទ ដូចមានចែងនៅ ក្នុងមាត្រា ៣ ជំពូកទី ១ នៃព្រះរាជក្រម ត្រូវបានកំណត់ដូចខាងក្រោម ÷

**១_របៀបគិតរយៈពេលបំរើការងារ :**

ការគិតរយៈពេលបំរើការងារ គឺបានគិតរួមទាំងរយៈពេលបំរើការងារគ្រប់របបសង្គម "បើមាន "និងរយៈពេលបំរើការងារស៊ីវិល និងកងយោធពលខេមរភូមិន្ទ ។

**ក_ត្រូវចាត់ទុកជារយៈពេលបំរើការងារ :**

- ការចាត់ទុកជារយៈពេលបំរើការងារ គឺគិតចាប់តាំងពីមន្ត្រី រាជការ កម្មកររដ្ឋដែល បានបញ្ចូលទៅក្នុងក្របខ័ណ្ឌ " រដ្ឋពេញសិទ្ធិ " រួចក្រោយមកចូលបំរើក្នុងកងយោធពលខេមរភូមិន្ទ ឬ ចាប់ពីពេលចូលបំរើក្នុងកងយោធពលខេមរភូមិន្ទជាប់រហូតដល់ពេលចូលនិវត្តន៍ ក៏ដូចជាត្រូវបានទទួលរបបចាត់បង់សមត្ថភាពការងារត្រូវបានគិតជាក់ស្តែងដូចខាងក្រោម ÷

_រយៈពេលធ្វើរដ្ឋបាល ភូមិ ឃុំ សង្កាត់ឬងជីវពលដែលមានប្រាក់ឧបត្ថម្ភ ។

_រយៈពេលមន្ត្រី រាជការ កម្មកររដ្ឋ ធ្វើការតាមក្រសួង ស្ថាប័នរដ្ឋនានា ឬរយៈពេល ទៅធ្វើកម្មសិក្សាក្នុង ឬ ក្រៅប្រទេស ។

_រយៈពេលមន្ត្រី រាជការ ធ្វើការងារក្រៅប្រទេស ។

_រយៈពេលបំរើការងារអតីតភាព តាមរបបសង្គម ។

_រយៈពេលបំរើការងារក្នុងចលនាតស៊ូ ។

_រយៈពេលជាប់មន្ទីរឃុំឃាំង ដោយគ្មានទោសកំហុស ។

_រយៈពេលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ ។

**ខ_មិនត្រូវចាត់ទុកជារយៈពេលបំរើការងារ :**

- គឺជារយៈពេលដែលតម្រូវអោយមន្ត្រីរាជការ កម្មកររដ្ឋធ្វើការសាកល្បង ។

**២_ការកំណត់ តំបន់លំបាក ការងារគ្រោះថ្នាក់ ឬ ការងារប៉ះពាល់សុខភាព មានដូចខាង ក្រោម ÷**

**ក_តំបន់លំបាក :**

-យោធិនបានបំពេញភារកិច្ចនៅតំបន់ដាច់ស្រយាល ឬ កោះ តំបន់គ្រុនចាញ់ តំបន់ព្រៃភ្នំ លំបាកដោយធាតុអាកាស ឬ លំបាកដោយជីវភាពរស់នៅ និងសមរភូមិប្រយុទ្ធ......។

**ខ_ការងារគ្រោះថ្នាក់ :**

យោធិនជាអាកាសយានិក ទ័ពជំនាញ " ឆ័ត្រយោង " ទ័ពវិស្វកម្ម " ជំនាញដោះមីន ទ័ពជំនាញផលិត ឬ ពិសោធន៍គ្រឿងផ្ទុះ ។

**គ_ការខាតបង់សុខភាព :**

យោធិនជានាវិក ជាងផ្សាដែក ជាងជួសជុលគ្រឿងចក្រធុនធ្ងន់ បុគ្គលិករ៉ាដា ជាងអគ្គិសនី អ្នកធ្វើការងារនៅអាគារជម្រឹផ្លូង អាគារថតឆ្លុះ និងមន្ទីរពិសោធន៍ " មន្ទីរពេទ្យ " ទ័ពជំនាញគីមីសាស្ត្រ ជំនាញកាំភ្លើងធំ អ្នកបើកបរគ្រឿងចក្រធុនធ្ងន់......។

ដើម្បីអនុវត្តអោយបានល្អ ហើយនិងមានប្រសិទ្ធភាពនោះ គឺក្រសួងការពារជាតិ ត្រូវធ្វើសេចក្តីកំណត់លំអិតអំពីល័ក្ខខ័ណ្ឌជាក់ស្តែង ។

**មាត្រា ៣ ._** បៀវត្សរ៍ឋានន្តរសក្តិត្រូវបានបូកបន្ថែមជាមួយ : ប្រាក់ហូបប្រចាំខែ ប្រាក់បំណាច់មុខងារ " បើមាន "ដើម្បីគិតប្រាក់សោធននិវត្តន៍ ហើយនិងបានទទួលប្រាក់បំណាច់តំបន់ " បើមាន "" គិតលើប្រាក់សោធននិវត្តន៍ផ្ទាល់ខ្លួន " ។

**មាត្រា ៤ ._** យោធិនទាំង ២ ភេទ ដែលមានគ្រប់ល័ក្ខខ័ណ្ឌត្រូវបានទទួលរបបសោធននិវត្តន៍ជាប្រចាំខែ ហើយដូចមានចែងក្នុងមាត្រា ៥ និងមាត្រា ៦ ជំពូកទី ១ នៃព្រះរាជក្រម ។ ក្រៅពីទទួលរបបសោធននិវត្តន៍ជាប្រចាំខែ ដូចដែលបានបញ្ជាក់ក្នុងប្រយោគទី ១ ខាងលើ យោធិនទាំង ២ ភេទត្រូវបានទទួលរបបមួយចំនួនទៀតដូចខាងក្រោម ÷

១_អ្នកនៅក្នុងបន្ទុកដែលរដ្ឋទទួលស្គាល់ មានសិទ្ធិទទួលរបបដូចនៅពេលបំរើការងារ ។

២_ចំពោះនាយទាហានថ្នាក់ ឧត្តមសេនីយ ឬ វិរៈជន ដែលមានអ្នកបើកបររថយន្ត និងកងការពារ ត្រូវបានរាជរដ្ឋាភិបាលពិនិត្យ និងដោះស្រាយជាក់ស្តែង ។

៣_ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និងអាជ្ញាធរមានសមត្ថកិច្ចមានភារកិច្ច ពិនិត្យលទ្ធភាពជួយរកការងារធ្វើអោយនិវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារដែលមានលទ្ធភាពបន្តការងារទៀតបាន ដោយផ្អែកទៅតាមសំណើ និង ជំនាញរបស់សាម៉ីខ្លួន ។

**មាត្រា ៥ ._** យោធិនទាំង ២ ភេទ មុនពេលចូលនិវត្តន៍អាចបានឈប់សំរាកច្បាប់ ដោយមានករណីចាំបាច់ ដើម្បីប្រុងប្រៀបជីវភាពរស់នៅក្នុងគ្រួសារ ទើបអនុញ្ញាតអោយ

ឈប់សំរាកបាន ដូចមានចែងក្នុងមាត្រា ៦ ចំណុច ២ ជំពូកទី ១ នៃព្រះរាជក្រម នឹងត្រូវបានកំណត់ដូចខាងក្រោម ÷

-យោធិនដែលមានឋានន្តរស័ក្តិពី ព្រិន្ទបាលឯក ចុះ ត្រូវបានឈប់សំរាក ៦ ខែ ។

-យោធិនដែលមានឋានន្តរស័ក្តិ នាយចំណង់ និងអនុសេនីយ៍ ត្រូវបាន ឈប់សំរាក ៨ ខែ ។

-យោធិនដែលមានឋានន្តរស័ក្តិ វរៈសេនីយ៍ ត្រូវបានឈប់សំរាក ១០ ខែ ។

-យោធិនដែលមានឋានន្តរស័ក្តិ ឧត្តមសេនីយ៍ ត្រូវបានឈប់សំរាក១២ ខែ ។

នៅពេលទៅសំរាកច្បាប់ក្នុងប្រទេសត្រូវទទួលប្រាក់ធ្វើដំណើរ ប្រាក់ហូបចុក តាមផ្លូវ ទាំងទៅទាំងមក តាមការកំណត់របស់ក្រសួងការពារជាតិ ។

**មាត្រា ៦ ._** និវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារ មានសិទ្ធិស្លៀកពាក់ឯកសណ្ឋាន កងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា ៧ ជំពូកទី ១ នៃព្រះរាជក្រម ដើម្បីជាកិត្តិយសក្នុងពិធីបុណ្យជាតិផ្សេងៗ ។ ការបើកផ្តល់ឯកសណ្ឋានកងយោធពលខេមរភូមិន្ទនេះ នឹងប្រព្រឹត្តទៅតាមការកំណត់របស់ ក្រសួងការពារជាតិ ។

**មាត្រា ៧ ._** សមត្ថកិច្ចនៃការសំរេចអោយបន្តការងារទៀត ឬ សំរេចអោយចូលនិវត្តន៍បាន ដូចមានចែងក្នុងមាត្រា ៨ ជំពូកទី ១ នៃព្រះរាជក្រម ព្រមទាំងអោយទទួលសោធនបាត់បង់សមត្ថភាពការងារត្រូវបានកំណត់ដូចខាងក្រោម ÷

១_តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ចំពោះយោធិនទាំង ២ ភេទ ចាប់ពី វរៈសេនីយ៍ទោ ឬ វរៈនាវីទោចុះ ។

២_តាមអនុក្រឹត្យដោយមានសំណើពីរដ្ឋមន្ត្រីក្រសួងការពារជាតិចំពោះយោធិនទាំង ២ ភេទថ្នាក់វរៈសេនីយ៍ឯក ឬ វរៈនាវីឯក ។

៣_តាមព្រះរាជក្រឹត្យដោយមានសំណើពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ចំពោះយោធិនទាំង ២ ភេទ ថ្នាក់ឧត្តមសេនីយ៍ ។

៤_យោធិនទាំង ២ ភេទ ដែលបានបំពេញគ្រប់លក្ខខ័ណ្ឌ នៃរយៈពេលបំរើការងារ តែអាយុពុំទាន់គ្រប់ចូលនិវត្តន៍ មានសិទ្ធិចូលនិវត្តន៍ភ្លាម ។ ផ្ទុយទៅវិញយោធិនទាំង ២ ភេទ ដែលចង់បន្តការងាររហូតគ្រប់លក្ខខ័ណ្ឌអាយុចូលនិវត្តន៍ ត្រូវសុំអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

## ជំពូកទី ២

## របបសោធនបាត់បង់សមត្ថភាពការងារ

**មាត្រា ៨ .–** យោធិនទាំង ២ ភេទ នៃកងយោធពលខេមរភូមិន្ទ ដែលអាចទទួលរបបបាត់បង់សមត្ថភាពការងារបានជាប្រចាំខែ លុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា ៩ និងមាត្រា ១២ ជំពូកទី ២ នៃព្រះរាជក្រម ។

អំពីរបៀបគិតរយៈពេលបំរើការងារ ព្រមទាំងការកំណត់តំបន់លំបាកការងារគ្រោះថ្នាក់ ឬ ការងារប៉ះពាល់សុខភាព គឺត្រូវអនុវត្តតាមការកំណត់ដូចមានចែងក្នុងមាត្រា ២ ជំពូកទី ១ នៃអនុក្រឹត្យនេះ ។

**មាត្រា ៩ .–**ល័ក្ខខ័ណ្ឌជាក់ស្តែងនៃការកើត នូវលក្ខណៈបាត់បង់សមត្ថភាពការងាររបស់ យោធិនតាមថ្នាក់នីមួយៗ ដូចមានចែងក្នុងមាត្រា ១០ ជំពូកទី ២ នៃព្រះរាជក្រមត្រូវបានកំណត់ដោយប្រកាសរួមអន្តរក្រសួង របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ១០ .–** បៀវត្សរ៍ឋានន្តរស័ក្តិត្រូវបានបូកបន្ថែមជាមួយ : ប្រាក់ហូបប្រចាំខែប្រាក់បំណាច់មុខងារ "បើមាន" ដើម្បីគិតប្រាក់សោធនបាត់បង់សមត្ថភាពការងារ ហើយនិងបានទទួលប្រាក់បំណាច់តំបន់ " បើមាន " គិតលើប្រាក់សោធនបាត់បង់សមត្ថភាពការងារផ្ទាល់ខ្លួន ។

**មាត្រា ១១ .–**យោធិនទាំង ២ ភេទ ដែលអាចទទួលរបបបាត់បង់សមត្ថភាព ការងារជាប្រចាំខែបានលុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១២ និងមាត្រា ១៣ ជំពូកទី ២ នៃព្រះរាជក្រម ។

ក្រៅពីរបបដែលបានបញ្ជាក់ក្នុងប្រយោគទី ១ ខាងលើ យោធិនទាំង ២ ភេទត្រូវបានទទួលរបបដូចមានចែងក្នុងមាត្រា ៤ ( ចំណុច ១ ២ ៣ ) និងមាត្រា ៦ ជំពូកទី ១ នៃអនុក្រឹត្យ នេះ ។

**មាត្រា ១២ .–**យោធិនបាត់បង់សមត្ថភាពការងារដែលគ្មានទីបង្អែក ដូចមានចែងក្នុងមាត្រា ១៣ (ចំណុច២) ជំពូកទី២ នៃព្រះរាជក្រម រដ្ឋទទួលបន្ទុកយកទៅស្នាក់នៅ មជ្ឈមណ្ឌលរបស់រដ្ឋ ឬ និវត្តជន ចាស់ជរារស់នៅតែលតោលគ្មានទីបង្អែក ក៏មានសិទ្ធិដូចជនបាត់បង់សមត្ថភាពការងារដែរ ។

ចំពោះប្រាក់សោធននិវត្តន៍ ឬ សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ត្រូវកាត់យក ស្មើនឹង ៥០ ភាគរយ ដើម្បីធានាការហូបចុក បើសិនជាខ្វះខាតរដ្ឋ បំពេញបន្ថែម ។ ចំពោះ យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី ១ បើសិនទៅរស់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ប្រាក់ឧបត្ថម្ភសំរាប់អ្នកជំនួយកិច្ចការក្នុងផ្ទះ មិនបាន បើកផ្តល់អោយឡើយ ។

**មាត្រា ១៣** .- ក្រោយពេលនិវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារ ទទួលមរណភាព គ្រួសារអ្នកទាំងនេះត្រូវបានដោះស្រាយរបបឧបត្ថម្ភមួយលើកតត់ដូចមានចែងក្នុងមាត្រា ១៤ ជំពូកទី ២ នៃព្រះរាជក្រមលេខ ០៧ នស.៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន ។

## ជំពូកទី ៣
## សមត្ថកិច្ច នៃការគ្រប់គ្រង និង បើករបបសោធននិវត្តន៍ និង របបសោធនបាត់បង់សមត្ថភាពការងារ

**មាត្រា ១៤** .- ជារៀងរាល់ឆ្នាំ ក្រសួងការពារជាតិ ត្រូវស្រង់បញ្ជីឈ្មោះយោធិនចូលនិវត្តន៍ និង យោធិនបាត់បង់សមត្ថភាពការងារ ជូនក្រសួងសេដ្ឋកិច្ច -ហិរញ្ញវត្ថុ និង ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ដើម្បីបំរុងថវិកាក្នុងការបើកផ្តល់សោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាព ការងារ ។

-ការគ្រប់គ្រង និង បើកចែករបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន រហូតដល់ពេលបង្កើតបានបេឡាសោធន ។

-ក្រសួងការពារជាតិមានភារកិច្ចបើកប្រាក់ឧបត្ថម្ភ ១ លើក ជូនដល់និវត្តជន ឬ ជនបាត់បង់សមត្ថភាពការងារនៃកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ មុនពេលផ្ទេរទៅអោយក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

មាត្រា ១៥ .– សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច_ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន និងអភិបាលខេត្ត_ក្រុងទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថ លេខានេះតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និងត្រា** | **ហត្ថលេខា និង ត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៦

## អនុក្រឹត្យ លេខ : ១១ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់សំណង់ទារីរអគ្គិសនីស្ទឹងមេទឹក (មណារម) នៃព្រះរាជាណាចក្រកម្ពុជា

* * *

## រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។

– យោងតាមព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

– យោងតាមព្រះរាជក្រឹត្យលេខ ន.ស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល